ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 06 / 2012
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/71

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ:

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ០២ ខែ ឧសភា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្ដី - ថ្ងៃទី ៥៩

រៀបចំដោយ: ឌុច ផារី និង Faiza ZOUAKRI

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Matteo CRIPPA, លោក ដាវ អានសាន |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ច័ន្ទ តារាស្មី, លោក វ៉េង ហ៊ាត់, លោក Vincent DE WILDE D'ESTMAEL, លោក Dale LYSAK |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN, លោក |

| |
|---|
| Jasper PAUW |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោក វែន ពៅ, លោកស្រី ទី ស្រីនណា លោក គីម ម៉េងឃី, លោកស្រី មេធាវី Laure DESFORGES, លោក Barnabé NEKUIE |
| សាក្សី៖ លោក នី កន TCW-487 |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Alexandra PRASSOLOFF |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ២០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សំណើទាក់ទងនឹងចៅក្រម CARTWRIGHT | មេធាវីការពារក្តី នួន ជា | ៩.១០ | ៩.២០ |
| ការតាំងសំណួរដល់សាក្សី សាឡុត បាន TCW-586 | មេធាវីការពារក្តី ខៀវ សំផន | ៩.២០ | ៩.៥០ |
| សំណើរបស់មេធាវីការពារក្តីធ្វើឡើងតាមវិធាន ២៨ (៩) ទាក់ទងនឹងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង | មេធាវីការពារក្តី នួន ជា សហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ៩.៥៥ | ១០.១០ |

00813558



| | | | |
|---|---|---|---|
| | អង្គជំនុំជម្រះ | | |
| ការជំទាស់ទៅលើភាពអាចទទួលយកបាននៃឯកសារ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ១០.១០ | ១០.២៥ |
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ១០.២៥<br>១២.១០ | ១០.២៥<br>១២.១០ |
| សវនាការជាអសាធារណៈធ្វើឡើងអនុលោមតាមវិធាន ២៨ (៨) | អង្គជំនុំជម្រះ | ១១.២០ | ១២.១០ |
| ការតាំងសំណួរដល់សាក្សី ពាន ឃាន TCW-504 | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១៣.៣៥<br>១៣.៤៩ | ១៣.៤៨<br>១៦.០០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**សំណើទាក់ទងនឹងចៅក្រម** CARTWRIGHT

មេធាវីការពារក្តី នួន ជា ធ្វើការកត់សម្គាល់ថា ពួកគេព្យាយាមយល់អំពីអាកប្បកិរិយារបស់ចៅក្រម CARTWRIGHT ក្នុងអំឡុងពេលសវនាការកាលពីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ នឹងស្នើសុំដល់អង្គជំនុំជម្រះឲ្យធ្វើការណែនាំដល់ចៅក្រម CARTWRIGHT មិនឲ្យសំដែងនូវអាកប្បកិរិយាដែលបង្ហាញនូវភាពលំអៀង។ អង្គជំនុំជម្រះសម្រេចបដិសេធទៅលើសំណើដែលធ្វើឡើងដោយមិនមានមូលដ្ឋានច្បាស់លាស់នេះ ។

**ការតាំងសំណួរដល់សាក្សី សាឡុត បាន** TCW-586 **(បន្តពីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២)**

មេធាវីការពារក្តី ខៀវ សំផន បញ្ចប់ការសួរសំណួរដល់សាក្សី សាឡុត បាន។

**សំណើរបស់មេធាវីការពារក្តីធ្វើឡើងតាមវិធាន ២៨ (៨) ទាក់ទងនឹងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង**

មេធាវីការពារក្តី នួន ជា ស្នើសុំធ្វើសវនាការជាអសាធារណៈដើម្បីពិភាក្សាអំពីបញ្ហាសក្ខីកម្មរបស់សាក្សី ពាន ឃាន ដែលអាចឈានទៅដល់ការដាក់បន្ទុកលើខ្លួនឯង ។ អង្គជំនុំជម្រះយល់ព្រមតាមសំណើ ។

មេធាវីការពារក្តី នួន ជា បានលើកឡើងនូវឯកសារមួយចំនួនដូចជា D224.24, D224.15, D125/143, D125/144, និង D125/207 ហើយដែលឯកសារទាំងនេះ ប្រសិនបើអានស្របពេលជាមួយនឹងការពិនិត្យលើឯកសារ E187.1 នោះ វាអាចនឹងមាននូវសក្ខីកម្មដែលអាចឈានទៅដល់ការដាក់បន្ទុកលើខ្លួនឯង។

**ការជំទាស់ទៅលើភាពអាចទទួលយកបាននៃឯកសារ**

មេធាវីការពារក្តី អៀង សារី ជំទាស់ទៅលើការប្រើឯកសារ E187.1 ដោយបានបង្ហាញមូលហេតុថា ឯកសារនេះមិនមែនជាបទសម្ភាសន៍ដែលបានធ្វើជាមួយសាក្សី ពាន យាន នោះទេ ប៉ុន្តែឯកសារនោះ គឺគ្រាន់តែជាអត្ថបទសង្ខេប ហើយមិនព័ត៌មានណាមួយដែលបង្ហាញ ថាតើឯកសារនេះត្រូវបានបង្កើតឡើង យ៉ាងដូចម្តេចនោះទេ។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួម សវនាការដោយផ្ទាល់ តែសុំចូលរួមសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ។

**សវនាការជាអសាធារណៈ (ធ្វើឡើងអនុលោមតាមវិធាន ២៨ (៨))**

អង្គជំនុំជម្រះធ្វើសវនាការជាអសាធារណៈ ដើម្បីពិភាក្សាលើសំណើរបស់មេធាវីការពារក្តី នួន ជា ដែល បានធ្វើឡើងតាមវិធាន ២៨ (៨) ។

**ការតាំងសំណួរដល់សាក្សី ពាន យាន TCW-504**

សហព្រះរាជអាជ្ញាតាំងសំណួរដល់សាក្សី ពាន យាន។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/446 | D369/36 | 00492957-00492972 00503160-00503172 00529506-00529520 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី LOT Nitya ឡុត និត្យា/SALOT Ban សាឡុត បាន/ SO Hong សូរ ហុង<br>Written Record of Interview of Witness LOT Nitya ឡុត និត្យា/SALOT Ban សាឡុត បាន/ SO Hong សូរ ហុង<br>Procès verbal d'audition de témoin LOT Nitya ឡុត និត្យា/SALOT Ban សាឡុត បាន/ SO Hong សូរ ហុង | P | 00492962, Question and answer 40 | 00503164, Question and answer 40 | 00529510, Question and answer 40 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (១០.២៥) និង នួន ជា (១២.១០) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនិងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទ ត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២។

**កាលបរិច្ឆេទបន្តសវនាការ៖**

សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បត្តិ៍ ទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ឆាវី Faiza ZOUAKRI